# ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ សម្រាប់ការពារការគោរពរដ្ឋធម្មនុញ្ញ ញបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបាន អនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ និង សម្រេចអំពីករណីវិវាទកម្មទាក់ទង នឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាព នៃ ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯក ភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ។

និមត្តសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញមានរូបព្រះព្រហ្មមានព្រះភ័ក្ត្រ៤ និងព្រះហស្ត ៤ កាន់ កេតនកណ្ឌ គង់លើបល្ល័ង្ក។ ព្រះព្រហ្ម ជានិមិត្តរូបនៃអ្នកបង្កើតលោក ។ ព្រះភ័ក្ត្រព្រះព្រហ្ម តំណាងឱ្យព្រហ្មវិហារធម៌ទាំងបួនគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា។ ព្រះហស្ត ឆ្វេង ខាងលើ កាន់ផ្កាឈូក តំណាងការកកើត ព្រះហស្ត ឆ្វេង ខាងក្រោមកាន់សាស្ត្រា តំណាងគម្ពីរក្បួន ច្បាប់ ព្រះហស្ត ស្តាំ ខាងលើកាន់ផ្គាំ តំណាងឱ្យការរំងាប់អារម្មណ៍ ការឧទ្ទិសកុសល ការចំរើន ភាវនា រកអំពើល្អ ផ្លូវធម៌ ផ្លូវលោក ព្រះហស្ត ស្តាំ ខាងក្រោមកាន់ពួចទឹក តំណាងទឹកអម្រិត ប្រោះព្រំ ឱ្យសុខសប្បាយត្រជាក់ត្រជុំ ឱ្យរស់ ។

### ១. ប្រវត្តិក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាពុំដែលមានប្រព័ន្ធត្រួតពិនិត្យធម្មនុញ្ញភាពទេ។ រដ្ឋធម្មនុញ្ញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៤៧ ដែលបានកែប្រែបន្តបន្ទាប់ រហូតដល់ ថ្ងៃទី ៣១ ខែមិនា ឆ្នាំ ១៩៦៤ ក៏បាននិយាយនៅក្នុងមាត្រា ១១៩ តែពីសិទ្ធិបកស្រាយអត្ថបទធម្មនុញ្ញ ហើយមិន មាននិយាយពីការត្រួត ពិនិត្យធម្មនុញ្ញភាពទេ ។ សិទ្ធិបកស្រាយចុងក្រោយជារបស់រដ្ឋសភា ។ រដ្ឋធម្មនុញ្ញសាធាណរដ្ឋខ្មែរ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧២ បានបង្កើតឱ្យ មានប្រព័ន្ធត្រួត ពិនិត្យធម្មនុញ្ញភាពមួយដែរដែលដាក់ឈ្មោះថា " តុលាការធម្មនុញ្ញ "។ ទោះបីជាមានឈ្មោះ

ជាតុលាការធម្មនុញ្ញក៏ដោយក៏អង្គការ នេះស្ថិតនៅដោយឡែកពីអង្គការតុលាការដែរ ។ ការបង្កើតនេះគឺពិតជាទទួលឥទ្ធិពល បស្ចឹមប្រទេសយ៉ាងប្រត្យក្ស។ ការមកដល់នៃរបបខ្មែរក្រហម នៅឆ្នាំ ១៩៧៥ បាននាំមកនូវការកាប់សម្លាប់ប្រជាជន និងកំទេចបំផ្លាញរចនាសម្ព័ន្ធទាំងអស់ព្រមទាំងជាន់ឈ្លីក្បួនច្បាប់ទាំងឡាយគ្មានសល់រហូតដល់ ដំណាច់ឆ្នាំ ១៩៧៨ ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ទន្ទឹមនឹងការកសាងប្រទេសជាតិឡើងវិញគ្រប់វិស័យការស្តារប្រព័ន្ធច្បាប់ក៏មានសកម្ម ភាពខ្លាំងក្លាណាស់ដែរ ។ រដ្ឋធម្មនុញ្ញសាធារណរដ្ឋ ប្រជាមានិតកម្ពុជាឆ្នាំ ១៩៨១ អនុញ្ញាតឱ្យមានការបកស្រាយច្បាប់ដោយក្រុមប្រឹក្សារដ្ឋក្នុងឋានៈ ជាអង្គការអចិន្ត្រៃយ៍ របស់រដ្ឋសភា ។ ចាប់ពីឆ្នាំ ១៩៨៩ ដល់ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃ រដ្ឋកម្ពុជាបាន ចែងអំពីការបកស្រាយ ច្បាប់ ដោយគណៈកម្មាធិការ អចិន្ត្រៃយ៍រដ្ឋសភា។ ប៉ុន្តែនៅពេលនោះការបកស្រាយរដ្ឋធម្មនុញ្ញ និងការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ពុំទាន់មាន នៅឡើយ។ រដ្ឋធម្មនុញ្ញថ្មីដែលបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញដែលកើតចេញពីការបោះឆ្នោតរៀបចំដោយអង្គការ សហប្រជាជាតិ ពីឆ្នាំ ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ។ នេះគឺជាការវិលត្រលប់ទៅរកឥទ្ធិពលបស្ចឹមប្រទេសជា ថ្មីម្តងទៀត ។

ជំពូក XII ថ្មីនៃរដ្ឋធម្មនុញ្ញចែងអំពី " ក្រុមប្រឹក្សាធម្មនុញ្ញ " ដែលមានចំណុចជាច្រើនធ្វើឱ្យគេនឹកគិតទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសបារាំង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមានចំណុចខុសគ្នា ពីបែបបារាំងដែរ ពិសេសការពិនិត្យធម្មនុញ្ញភាព នៃច្បាប់ក្រោយពេលដែលច្បាប់នោះ ត្រូវបាន ប្រកាសឱ្យប្រើហើយ និង សវនាការសាធារណៈនៅក្នុងការជំនុំជំរះ វិវាទទាក់ទង និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ សវនាការសា ធារណៈនេះមានចែងនៅក្នុងច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ ដែលបានប្រកាសឱ្យប្រើនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ។ គួរកត់សំ គាល់ដែរថា រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ២លើកមកហើយ លើកទី ១ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ១៩៩៤ ដើម្បីធ្វើ ប្រតិភូកម្មព្រះហស្តលេខាព្រះមហាក្សត្រទៅជូនប្រមុខរដ្ឋស្តីទី និង លើកទី ២ នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៩៩ ដើម្បីបង្កើតព្រឹទ្ធសភា ។

## ២. ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញបានចាប់ដំណើរការពេញលក្ខណៈនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ១៩៩៨ ជាលើកទីមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា។

### ២.១ សមាសភាព

សមាសភាពនៃក្រុមប្រឹក្សាធម្មនុញ្ញមានប្រធាន ១ រូបនិងសមាជិកចំនួន ៨ រូប។ ប្រធានត្រូវបានជ្រើសតាំង ដោយ សហសេវិក (១) ទាំង ៩ រូបតាមមតិភាគច្រើនដាច់ខាតរៀងរាល់បីឆ្នាំម្តង ក្រោយពីសមាជិកថ្មី ៣ រូប ចូលកាន់តំណែង។ ប្រធានមាន ឋានៈ និងបុព្វសិទ្ធិស្មើ នឹងប្រធានរដ្ឋសភា។ សមាជិកមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។ ជាធម្មតាអាណត្តិរបស់សមាជិកគឺ ៩ ឆ្នាំ ប៉ុន្តែសមាជិកចំនួន ៣រូប ត្រូវបានជ្រើសតាំង ឬតែងតាំងរាល់បីឆ្នាំម្តង។ ក្នុងអាណត្តិទី១ ត្រូវបានតែងតាំង ឬជ្រើសតាំងសមាជិកខ្លះសម្រាប់បីឆ្នាំ ខ្លះសម្រាប់ប្រាំមួយឆ្នាំ និងខ្លះទៀតសម្រាប់ប្រាំបួនឆ្នាំ។ សមាជិក ៣ រូបតែងតាំងដោយ ព្រះមហាក្សត្រផ្ទាល់៣រូប ជ្រើសតាំងដោយរដ្ឋសភា និង ៣រូបទៀតជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងរយៈពេល ៣ឆ្នាំម្តង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ត្រូវផ្លាស់ប្តូរ និង តែងតាំង ជាថ្មី គឺតែងតាំងដោយព្រះមហាក្សត្រ ១រូប ជ្រើសតាំងដោយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ១រូប និង ជ្រើសតាំងដោយរដ្ឋសភា ១រូប ។ សមាជិកមកជំនួសថ្មី ដែលអាណត្តិ មានរយៈពេលតិចជាង ឬ ស្មើនឹង ៣ឆ្នាំ អាចត្រូវតែងតាំង ឬ ជ្រើសតាំងសម្រាប់មួយអាណត្តិទៀតបាន។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិ ស្មើនឹងប្រធានរដ្ឋសភាចំណែកឯសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា។

សមាជិកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ ឆ្នាំ មានបទពិសោធន៍ក្នុងកាងារយ៉ាងតិច ១៥ ឆ្នាំមានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ រដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច។

## ២.២ វិសមិភាព និងអភ័យឯកសិទ្ធិ

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយសកម្មភាពទាំងអស់នៅក្នុងមុខងារសាធារណៈនិងមុខងារជា សមាជិកព្រឹទ្ធសភា តំណាងរាស្ត្រ សមាជិករាជ រដ្ឋាភិបាល ប្រធាន និងអនុប្រធានគណបក្សនយោបាយ ប្រធាន និងអនុប្រធានសហជីព ចៅក្រមក្នុងមុខតំណែង។ នៅក្នុងអាណត្តិរបស់ខ្លួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបំពេញតំណែង ឬ មុខរបរណា មួយផ្សេងទៀតឡើយ។

អំពីអភ័យឯកសិទ្ធិ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬ បទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើឡើងនៅពេលបំពេញ ភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ ។

ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយពីតំណែង តម្រូវឱ្យមានការយល់ព្រមពី សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន ពីរភាគបី នៃចំនួនសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល នៅក្នុង សវនាការមិនសាធារណៈ និង ដោយមានវត្តមានរបស់សាមីខ្លួន។ ក្រុមប្រឹក្សាធម្មនុញ្ញអាចដកចេញពី តំណែងនូវសមាជិកណាដែលមាន វិសមិតភាពមុខតំណែង ឬ ដែលមិនបានមកប្រជុំលើសពីពដងផ្ទួនៗគ្នា ដោយឥតជូនដំណឹងជាមុន ឬ ដែលមិនអាចបំពេញមុខងារជារៀងរហូតបាន ដោយបាត់បង់សមត្ថភាព ខាងបញ្ញា ឬ រូបកាយជាអចិន្ត្រៃយ៍ ។

អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែ ស្របតាមលក្ខខណ្ឌ និងរូបមន្តសម្រាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រ ។

## ២.៣ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

កិច្ចប្រជុំនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកចំនួន ៥ រូប យ៉ាងតិចចូលរួមប្រជុំតាមការ កោះអញ្ជើញរបស់ប្រធាន ក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិកដែលមានអាយុច្រើនជាងគេ បើប្រធានមានធុរៈមិនអាចធ្វើ បាន។ ការកោះប្រជុំ

និងការដឹកនាំអង្គប្រជុំលើកទី១ របស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើឡើងដោយសមាជិក ដែលមានអាយុច្រើនជាងគេ ដែលបានធ្វើសច្ចា ប្រណិធាន និង ដែលមានអវត្តមាន (ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ) ។

បទបញ្ជាផ្ទៃក្នុងត្រូវបានអនុម័តដោយមតិភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល។ បទបញ្ជានេះកំណត់អំពីនីតិវិធីផ្ទៃក្នុងរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចែកជា ៣ក្រុម ដែលមួយក្រុមមានសមាជិក ៣រូប មកពីប្រភពតែងតាំង និង ជ្រើសតាំងទាំង៣ ។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចាត់តាំងសមាជិកម្នាក់ នៃក្រុមណាមួយជាសមាជិករាយការណ៍សម្រាប់ករណី នីមួយៗ ។

ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញដែលបានទទួលការចាត់តាំង ធ្វើការពិភាក្សាអំពី ការវិភាគ និង ទស្សនៈដែលសមាជិករាយការណ៍បានលើកជូន។ ក្រោយពីក្រុមបានពិភាក្សាចប់សព្វគ្រប់ហើយ ទោះបីការពិភាក្សានោះពុំបានចុះសម្រុងគ្នាក៏ដោយ សមាជិករាយការណ៍ត្រូវដាក់របាយការណ៍របស់ខ្លួនជូនសម័យប្រជុំបឋម នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានកំណត់កាលបរិច្ឆេទដោយប្រធានរួចហើយ។ សម័យប្រជុំបឋមគឺជាការប្រជុំរៀបចំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលសមាជិក ម្នាក់ៗអាចបញ្ចេញយោបល់របស់ខ្លួនប៉ុន្តែពុំមានការអនុម័តទេ។ នៅក្នុងអង្គប្រជុំនេះគេអាចដឹងបានអំពីនិន្នាការស្រប ឬ មិនស្របទៅនឹងសំណុំរឿងដែលបាន ពិនិត្យ។ ដំណាក់កាលចុងក្រោយ គឺសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលនឹងចេញសេចក្តីសម្រេចតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកទាំងមូល។ សម័យប្រជុំពេញអង្គនេះក៏អាចប្រែរូប ទៅជាសវនការជំនុំជម្រះជាសាធារណៈដែរ នៅក្នុងករណីខ្លះ ដែលមានចែងដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រ។ គ្រប់កិច្ចពិភាក្សាទាំងអស់នៅក្នុងអង្គប្រជុំទាំងនោះ ត្រូវចុះក្នុងកំណត់ហេតុ រៀបចំដោយ គណៈលេខាធិការ ដែលដឹកនាំដោយអគ្គលេខាធិការ ឬ អគ្គលេខាធិការរង។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរក្សាការសម្ងាត់ក្នុងការពិភាក្សា និង ការបោះឆ្នោត ហើយមិនត្រូវបញ្ចេញយោបល់របស់ខ្លួននៅក្រៅអង្គប្រជុំទេ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីតាមមតិភាគច្រើនដាច់ខាត នៃសមាជិកទាំងមូល (៥ សម្លេង) លើកលែងតែការដកតំណែង សមាជិក ក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវសម្រេចតាមមតិភាគច្រើនពីរភាគបីនៃសមាជិកទាំងមូល (៦ សម្លេង) ។

## ៣. សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

ជាគោលការណ៍ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ ។ មានតែ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន និងអ្នកតំណាងរាស្ត្រមួយភាគដប់ ឬតុលាការប៉ុណ្ណោះ ដែលអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ ធម្មនុញ្ញភាព នៃច្បាប់បាន ។ ប្រជារាស្ត្រ និងគណបក្សនយោបាយអាច លើកសំណើ ឬ ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញបានតាមល័ក្ខខ័ណ្ឌ ដែលមានចែង។

**ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចដូចខាងក្រោម ៖**

- ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។
- ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច ធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ហើយក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាព ។
- ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសំរេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ បណ្តឹងនេះធ្វើបានតែក្នុងរយៈពេល ៧២ ម៉ោង យ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ឬ តាមបណ្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ក្នុងការដោះស្រាយវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការដោះ

ស្រាយបណ្ដឹងតវ៉ា ឬ បណ្ដឹងជំទាស់នឹងបញ្ជីដំបូងនៃការចុះឈ្មោះបោះឆ្នោត និងការដោះស្រាយបណ្ដឹងក្នុងពេលឃោសនាបោះឆ្នោតក្រុមប្រឹក្សាធម្មនុញ្ញបំពេញតួនាទីដូច តុលាការ ។

- ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេចលើបណ្ដឹងតវ៉ា ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ។

- ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសាសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ ដែលមានសមត្ថកិច្ចសំរេចពីមោឃភាពនេះ។

- ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីអធម្មនុញ្ញភាព នៃច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញបាន តាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រចំនួនមួយភាគដប់។ បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្ដីណាមួយ ហើយរឿងក្ដីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាព នៃបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្ដីសំរេចរបស់ស្ថាប័ននានា ដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន។ ប្រជារាស្ត្រអាចលើកឡើងប្ដឹងទៅតុលាការ អំពីបញ្ហាអធម្មនុញ្ញភាពនៃច្បាប់ ឬ សេចក្ដីសម្រេចរបស់ស្ថាប័ននានារបស់រដ្ឋដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្ដីសម្រេចរដ្ឋបាលផ្សេងៗតាមរយៈរឿងក្ដីរបស់ខ្លួននៅតុលាការ។ តុលាការថ្នាក់ក្រោមបញ្ជូនពាក្យបណ្ដឹងខាងលើនេះទៅតុលាការកំពូល។ តុលាការកំពូល ជាអ្នកបញ្ជូនបណ្ដឹងនោះបន្តមកក្រុមប្រឹក្សាធម្មនុញ្ញ បើសិនជាតុលាការកំពូល យល់ឃើញថាសមហេតុសមផល។ បញ្ហាដែលកើតឡើងនោះជាបញ្ហាបន្ទាន់បង្ខំដែលតុលាការទទួលបន្ទុកជំនុំជម្រះត្រូវផ្អាកសិនដោយរង់ចាំចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាមុន។ ក្នុងករណីគ្មានរឿងក្ដីក៏ដោយ ប្រជារាស្ត្រមានសិទ្ធិប្ដឹងសុំឱ្យពិនិត្យធម្មនុញ្ញភាព នៃច្បាប់ណាដែលប្រកាសឱ្យប្រើហើយ។ ប្រជារាស្ត្រត្រូវប្ដឹងតាមរយៈ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬ តំណាងរាស្ត្រចំនួនមួយភាគដប់។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និង សម្រេចជូន ប្រជារាស្ត្រអំពីករណីវិវាទកម្មទាក់ទងនឹងរឿងបោះឆ្នោតជ្រើស

តាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាក្នុងករណី ដែលប្រជារាស្ត្រមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ។

**៤. អ្នកមានសិទ្ធិដាក់សំណើ ឬ បណ្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ**

ក្រុមប្រឹក្សាធម្មនុញ្ញទទួលពិនិត្យ ដោះស្រាយសំណើ ឬបណ្តឹងជានិច្ចជាកាលតាមរយៈនៃ ការស្នើសុំពីខាងក្រៅមិនមែនក្រុមប្រឹក្សាធម្មនុញ្ញខ្លួនឯងចាប់យកមក ពិនិត្យវិនិច្ឆ័យដោយឯកឯងនោះទេ។ អ្នកដែលមានសិទ្ធិក្នុងការធ្វើបណ្តឹង ឬ លើកសំណើត្រូវបានបែងចែកដោយឡែកៗ ទៅតាមប្រភេទ និងកម្មវត្ថុនៃបណ្តឹង ឬ សំណើរដូចមានខាងក្រោម ៖

**ក. អ្នកមានសិទ្ធិដាក់សំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ការបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ឬ ព្រឹទ្ធសភា**

| ប្រភេទ កម្មវត្ថុនៃសំណើ | សមាសភាពអ្នកមានសិទ្ធិដាក់សំណើ |
|---|---|
| **១. ពិនិត្យធម្មនុញ្ញ ជាអាទិកាល (មុនពេលដែលច្បាប់ប្រកាសឱ្យប្រើ)**<br>**ក. មិនដាច់ខាត**<br>- ច្បាប់ស្តីពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ អនុសញ្ញាអន្តរជាតិ<br>- ច្បាប់ធម្មតា | - ព្រះមហាក្សត្រ<br>- ប្រធានព្រឹទ្ធសភា<br>- ប្រធានរដ្ឋសភា<br>- នាយករដ្ឋមន្ត្រី<br>- តំណាងរាស្ត្រ ចំនួន ១ ភាគ ១០<br>- សមាជិកព្រឹទ្ធសភា ចំនួន ១ ភាគ ៤ |
| **ខ. ជាដាច់ខាត**<br>- បទបញ្ជាផ្ទៃក្នុង វិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា<br>- បទបញ្ជាផ្ទៃក្នុង វិសោធនកម្មបទបញ្ជាផ្ទៃក្នុង | <br>- ប្រធានព្រឹទ្ធសភា<br>- ប្រធានរដ្ឋសភា<br>- ប្រធានរដ្ឋសភា |

| | |
|---|---|
| របស់រដ្ឋសភា<br>- ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការ | |
| **២. ពិនិត្យធម្មនុញ្ញភាព ជាបច្ឆាកាល** (ក្រោយពេលដែលច្បាប់ប្រកាសឱ្យ ប្រើ)<br>- ព្រះរាជក្រម ក្រឹត្យ-ច្បាប់ដែលនៅជាធរមាន<br>- បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងរដ្ឋសភា<br>**៣. បកស្រាយ**<br>- រដ្ឋធម្មនុញ្ញ<br>- ព្រះរាជក្រម ក្រឹត្យ-ច្បាប់ដែលនៅជាធរមាន<br>- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង រដ្ឋសភា | - ព្រះមហាក្សត្រ<br>- ប្រធានព្រឹទ្ធសភា<br>- ប្រធានរដ្ឋសភា<br>- នាយករដ្ឋមន្ត្រី<br>- តំណាងរាស្ត្រ ចំនួន ១ ភាគ ១០<br>- សមាជិកព្រឹទ្ធសភា ចំនួន ១ ភាគ ៤<br>- តុលាការ<br>- ប្រជារាស្ត្រធ្វើសំណើ ប៉ុន្តែពុំដោយផ្ទាល់ទេ ត្រូវឆ្លងតាមរយៈ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា សមាជិកព្រឹទ្ធសភា ១ ភាគ ៤ តំណាងរាស្ត្រ ១ ភាគ១០ |

### ខ. អ្នកមានសិទ្ធិដាក់បណ្តឹងតវ៉ាដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនិងសំរេចលើបណ្តឹងតវ៉ាពីសេចក្តីសំរេចរបស់គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប)តែប៉ុណ្ណោះលើកលែងតែ ករណីប្តឹងអំពីលទ្ធផលបណ្តោះអាសន្ន ទើបបុគ្គលគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតអាចដាក់បណ្តឹងដោយផ្ទាល់មកក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ម៉ោងបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន ក្នុងករណីដែលបណ្តឹងនេះមិនបានដាក់ប្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសំរេចលើបណ្តឹងតវ៉ាការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ។

| ប្រភេទកម្មវត្ថុនៃបណ្តឹង | សមាសភាពអ្នកមានសិទ្ធិដាក់បណ្តឹង |
|---|---|

| | |
|---|---|
| ១-ការចុះបញ្ជី គណបក្សនយោបាយនៅក្រសួងមហាផ្ទៃ | គណបក្សនយោបាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា(៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ពីក្រសួងមហាផ្ទៃ។ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យសំរេច ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបណ្តឹង) |
| ២-ការតវ៉ាពីបេក្ខភាព បញ្ជីរាយនាមបេក្ខជន | សាមីខ្លួន សាមីគណបក្សនយោបាយ(៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួល លិខិតជូនដំណឹងបដិសេធពី គជប។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសំរេច ក្នុងរយៈពេល១០ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលបណ្តឹង) |
| ៣-ការសុំចុះឈ្មោះបោះឆ្នោត<br>- ការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត<br>- ជំទាស់នឹងការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត<br>- ការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត | សាមីខ្លួនអ្នកតំណាងឱ្យសាមីខ្លួន (៥ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធពី គជប។ ក្រុមប្រឹក្សាធម្មនុញ្ញសំរេចក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលបណ្តឹង) |
| ៤-លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត<br>- បណ្តឹងតវ៉ាដោយផ្ទាល់ ៧២ ម៉ោងយ៉ាងយូរបន្ទាប់ពី ការប្រកាសលទ្ធផលបណ្តោះអាសន្ន របស់ គជប<br>- បណ្តឹងជំទាស់នឹងសេចក្តីសំរេច របស់ គជប ៧២ម៉ោងយ៉ាងយូរ បន្ទាប់ពីការជូនដំណឹងរបស់ គជប | គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត<br>ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យសំរេចក្នុងរយៈពេល ១០ថ្ងៃ ទៅ២ |